**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ២០៦៤ ..... សហវ.[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ២០១៥

## ជម្រាបជូន

## លោកបណ្ឌិត ប្រធាននាយកប្រតិបត្តិ ធនាគារ អេស៊ីលីដា ភីអិលស៊ី

**កម្មវត្ថុ:** ករណីការអនុញ្ញាតឱ្យក្រសួង ស្ថាប័ន អង្គភាព មន្ទីរជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បើកគណនីចរន្តជាប្រាក់រៀលនៅធនាគារ អេស៊ីលីដា ភីអិលស៊ី និងសាខាធនាគារនៅរាជធានី ខេត្ត។

**យោង:** អនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីការប្រើប្រាស់សេវាកម្មរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់ប្រតិបត្តិការចំណូល ចំណាយថវិការដ្ឋអនុវត្តនៅទូទាំងប្រទេស ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារ អេស៊ីលីដា ភីអិលស៊ី។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប លោកបណ្ឌិត ជ្រាបថា៖ ដើម្បីបង្កើនប្រសិទ្ធភាពសម្រាប់កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាតាមរយៈការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ការទូទាត់ត្រង់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុញ្ញាតឱ្យក្រសួង ស្ថាប័ន អង្គភាព មន្ទីរជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បើកគណនីចរន្តជាប្រាក់រៀលនៅធនាគារ អេស៊ីលីដា ភីអិលស៊ី និងសាខាធនាគារនៅរាជធានី ខេត្ត ដូចខាងក្រោម៖

នៅថ្នាក់កណ្ដាល៖

- អង្គភាពថវិកានីមួយៗ នៅក្រោមចំណុះក្រសួង ស្ថាប័ន ដែលអនុវត្តថវិកាកម្មវិធី ត្រូវបានអនុញ្ញាតឱ្យបើកគណនីចរន្តជាប្រាក់រៀលចំនួន ០១ (មួយ) សម្រាប់ប្រតិបត្តិការថវិកាកម្មវិធី ហើយប្រធានអង្គភាពថវិកាជាម្ចាស់គណនី។
- សម្រាប់ថវិការបស់ក្រសួង ស្ថាប័ន ដែលអនុវត្តថវិកាកម្មវិធី (ក្រៅពីអង្គភាពថវិកា) ត្រូវបានអនុញ្ញាតឱ្យបើកគណនីចរន្តជាប្រាក់រៀលចំនួន ០១ (មួយ) សម្រាប់ប្រតិបត្តិការថវិកា ហើយរដ្ឋមន្ត្រី ប្រធានស្ថាប័នជាម្ចាស់គណនី។

នៅថ្នាក់រាជធានី ខេត្ត ៖

- មន្ទីរជំនាញនៅថ្នាក់រាជធានី ខេត្ត ត្រូវបានអនុញ្ញាតឱ្យបើកគណនីចរន្តជាប្រាក់រៀលចំនួន ០១ (មួយ) សម្រាប់ប្រតិបត្តិការរជ្ជទេយ្យបុរេប្រទាន ហើយប្រធានមន្ទីរជាម្ចាស់គណនី។
- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានអនុញ្ញាតឱ្យបើកគណនីចរន្តជាប្រាក់រៀលចំនួន ០១ (មួយ) សម្រាប់ប្រតិបត្តិការរជ្ជទេយ្យបុរេប្រទាន ហើយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាម្ចាស់គណនី។

- រដ្ឋបាលឃុំ សង្កាត់ ត្រូវបានអនុញ្ញាតឱ្យបើកគណនីចរន្តជាប្រាក់រៀលចំនួន ០១ (មួយ) សម្រាប់ប្រតិបត្តិការរដ្ឋទេយ្យបុរេប្រទាន ហើយមេឃុំ ចៅសង្កាត់ ជាម្ចាស់គណនី។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោកបណ្ឌិត ជ្រាប និងអនុញ្ញាត តាមការគួរ។

សូម លោកបណ្ឌិត ទទួលនូវការគោរពរាប់អាន ពីខ្ញុំ

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន:**

- *អគ្គនាយកដ្ឋានរតនាគារជាតិ*
- *គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញ*
- *រដ្ឋបាលថ្នាក់ក្រោមជាតិ*
  *"ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*

To: SVP & Head of OPD
for letter inform to
OPD & all branches.

22/4/2015
G.COO.

Dr. SO PHONNARY

//

# ធនាគារ អេស៊ីលីដា ភីអិលស៊ី

## ACLEDA Bank Plc.

**ការិយាល័យកណ្តាល**

លេខ : ធអក-ប្រក.......282........./១៥

ភ្នំពេញ, ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥

**អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ**

**ជម្រាបមក**

**- នាយកប្រតិបត្តិប្រតិបត្តិការ**

**- នាយក-នាយិកា គ្រប់សាខា**

**កម្មវត្ថុ : សេចក្តីជូនដំណឹង ស្តីពីការបើកគណនីចរន្តជាប្រាក់រៀល សម្រាប់ក្រសួង ស្ថាប័ន អង្គភាព មន្ទីរជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។**

**យោង** :

- សេចក្តីសម្រេចលេខ : ធអក ៥៦៣/១៣ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីការផ្លាស់ប្តូរមុខងារ **បណ្ឌិត សូ ផនណារី** ជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ ។
- លិខិតលេខ : ២៦៦៤ សហវ-អរតន ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- ដើម្បីឲ្យការបម្រើសេវារបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី មានប្រសិទ្ធភាពខ្ពស់ ។

តបតាមកម្មវត្ថុ និងយោងខាងលើ សូមលោកនាយកប្រតិបត្តិ និងលោកនាយក-នាយិកាសាខា ជ្រាបថា ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុញ្ញាតឲ្យក្រសួង ស្ថាប័ន អង្គភាព មន្ទីរជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បើកគណនីចរន្តជាប្រាក់រៀល សម្រាប់កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាជាតិ ដូចមានលិខិតភ្ជាប់មកជាមួយ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកនាយកប្រតិបត្តិ និងលោកនាយក-នាយិកាសាខា ជ្រាបជាព័ត៌មាន និងសហការអនុវត្តក្នុងការបើកគណនីនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

សូមលោកនាយកប្រតិបត្តិ និងលោកនាយក-នាយិកាសាខា ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**អនុប្រធាននាយកប្រតិបត្តិ**

**និងជា**

**គណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ**

**បណ្ឌិត សូ ផនណារី**

**ភ្ជាប់មកជាមួយនូវ:**

- លិខិតលេខ: ២៦៦៤ សហវ.អរតន ចំនួន "០១ច្បាប់"

**ចម្លងជូន:**

- សមាជិក-សមាជិកាគណៈកម្មាធិការប្រតិបត្តិ
- នាយិកាប្រតិបត្តិទីផ្សារ

**"ដើម្បីជ្រាបជាព័ត៌មាន"**

- ឯកសារ-កាលប្បវត្តិ

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.

ទូរស័ព្ទTel: +855 (0) 23 998 777 / 430 999, ទូរសារFax: +855 (0) 23 430 555, ប្រអប់សំបុត្រP.O.Box: 1149

E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP